**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តរតនគិរី**
**គណៈកម្មាធិការលទ្ធកម្មខេត្ត**
លេខ : ០១១/០១៨ ស.ជ.ណ

ថ្ងៃ សុក្រ ៥រោច ខែ ភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅខេត្តរតនគិរី ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការអញ្ជើញចូលរួមដេញថ្លៃការស្ថាបនាផ្លូវក្រាលកៅស៊ូ DBST លើកំណាត់ផ្លូវលេខ ៥០៣ ស្ថិតក្នុងភូមិ ៧មករា សង្កាត់ឡាបានសៀក និងផ្លូវភូមិថ្មី ក្នុងសង្កាត់យក្សឡោម ក្រុងបានលុង (ក្រាលក្រួសក្រហម ទទឹង ១១ម៉ែត្រ ប្រវែង ៨៦៤ម៉ែត្រ ស្មើនឹង ៩.៥០៤ម៉ែត្រការ៉េ និងទំហំផ្លូវក្រាលកៅស៊ូ ទទឹង ០៧ម៉ែត្រ ប្រវែង ៨៦៤ម៉ែត្រ ស្មើនឹង ៦.០៤៨ម៉ែត្រការ៉េ) ជូនរដ្ឋបាលខេត្តរតនគិរី**

រដ្ឋបាលខេត្តរតនគិរី សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា រដ្ឋបាលខេត្តរតនគិរី នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការស្ថាបនាផ្លូវក្រាលកៅស៊ូ DBST លើកំណាត់ផ្លូវលេខ ៥០៣ ស្ថិតក្នុងភូមិ ៧មករា សង្កាត់ឡាបានសៀក និងផ្លូវភូមិថ្មី ក្នុងសង្កាត់យក្សឡោម ក្រុងបានលុង (ក្រាលក្រួសក្រហម ទទឹង ១១ម៉ែត្រ ប្រវែង ៨៦៤ម៉ែត្រ ស្មើនឹង ៩.៥០៤ម៉ែត្រការ៉េ និងទំហំផ្លូវក្រាលកៅស៊ូ ទទឹង ០៧ម៉ែត្រ ប្រវែង ៨៦៤ម៉ែត្រ ស្មើនឹង ៦.០៤៨ម៉ែត្រការ៉េ) ជូនរដ្ឋបាលខេត្តរតនគិរី ។

រដ្ឋបាលខេត្តរតនគិរី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តរតនគិរី ដែលមានអាសយដ្ឋានភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ចាប់ពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៦១ ៣៣ ៧៧ ៩៩ ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១៨ វេលាម៉ោង ០៨:០០នាទីព្រឹក ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨:០០នាទី ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**អភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្មខេត្ត**

**ថង សាវុន**

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ